# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាមិនទក្កសាលាសន្តយ៉ូស្វីនជំនាន់៣នៅភ្នំពេញថ្មី
# ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨

*យើងរស់តាមរបៀបព្រះយេស៊ូ*

អត្ថបទទី១៖ សណ ២,២.១០-១៥.១៨-១៩
ដំណឹងល្អ៖ មថ ៨,៥-១៧

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងគោរពមរណសាក្សីសម័យដំបូង នៅទីក្រុងរ៉ូមជាពិសេសនៅឆ្នាំ៦៤ដែលទីក្រុងរ៉ូមបានឆេះអស់ ហើយចៅអធិរាជបានចោទប្រកាន់ថា នេះជាគ្រីស្តបរិស័ទដែលបានធ្វើឲ្យមានភ្លើងឆេះ គេបានចាប់គ្រីស្តបរិស័ទ និងសម្លាប់។ ក្នុងមួយអាទិត្យកន្លងមក យើងបានគោរពមរណសាក្សីពីដើមដំបូង យើងមានទេវវិទូតមួយដែលធ្លាប់និយាយថា "**ឈាមមរណសាក្សីជាពូជគ្រីស្តបរិស័ទ**" កន្លែងណាមានឈាមមរណសាក្សីកន្លែងនោះមានគ្រីស្តបរិស័ទដែលផុសឡើងដូចផ្សិត។

នៅពេលយើងទទួលការបៀតបៀនយើងទទួលកម្លាំងថែមទៀត ដើម្បីប្រកាសដំណឹងល្អ។ ថ្ងៃនេះរួមជាមួយមរណសាក្សីពីដើម យើងដឹងថាគ្រីស្តបរិស័ទរបស់យើងនៅទីនេះ មានមួយចំនួនធំដែលជាគ្រីស្តបរិស័ទជំនាន់ទីមួយថ្មី។ ព្រះសហគមន៍បានប្រកាសដំណឹងល្អនៅប្រទេសកម្ពុជាជាង៤៥០ឆ្នាំហើយ ប៉ុន្តែគ្រីស្តបរិស័ទនៅសល់ក្រោយសម័យប៉ុលពតមានតិចណាស់។ ដូច្នេះ យើងមានបងប្អូនយើងដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកពីឆ្នាំ១៩៩៨ ឆ្នាំ២០០៣ ឆ្នាំ២០០៥ ដែលជាគ្រីស្តបរិស័ទជំនាន់ដំបូង។ ដូចនៅទីក្រុងរ៉ូមនិងទីក្រុងយេរូសាឡឹមពីដើម យើងជាគ្រីស្តបរិស័ទដំបូងដើម្បីប្រកាសដំណឹងល្អ។ នៅក្នុងប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍យើង បានណែនាំឲ្យអ្វីៗទាំងអស់បាត់បង់ទាំងអស់យើងកើតសារជាថ្មី។ ដូច្នេះបងប្អូនដែលបានរៀននៅក្នុងសាលាអប់រំជំនឿសន្តយ៉ូស្វីនពីរឆ្នាំកន្លងមក យើងមិនបានរៀបលេងៗទេ យើងបានយកចិត្តទុកដាក់មានវត្តមានពីមួយអាទិត្យទៅមួយអាទិត្យ លោកគ្រូក៏មិនបានបង្រៀនលេងៗទេ ដើម្បីឲ្យយើងយល់ថា យើងជាគ្រីស្តបរិស័ទដែលទទួលមរតកនៃព្រះសហគមន៍ពីដើម ដើម្បីឲ្យមរតកនេះអាចរីកចម្រើនតទៅទៀតនៅលើទឹកដីកម្ពុជា។ ហេតុនេះហើយ យើងទទួលបេសកកម្មមួយពិសេស យើងត្រូវការពោរពេញដោយសេចក្តីក្លាហាន ដើម្បីរស់នៅជាគ្រីស្តបរិស័ទនៅក្នុងសង្គមបច្ចុប្បន្ននេះ។

នៅប្រទេសកម្ពុជា គ្មានអ្នកដែលសម្លាប់យើង ដែលបៀតបៀនយើង ដែលហាមយើងកាន់សាសនា កុំឲ្យយើងគិតថាបន្តិចទៀតយើងទទួលសញ្ញាបត្របញ្ជាក់ថា យើងបានរៀនចប់នៅសាលាសន្តយ៉ូស្វីន វាមិនសំខាន់ប៉ុន្មានទេ ដោយសារយើងមិនចូលស្ថានបរមសុខដោយសារសញ្ញាបត្ររបស់យើង។ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់ចំណេះដឹងដែលយើងបានទទួល ប៉ុន្តែឲ្យយើងប្រសញ្ញាបត្រនេះធ្វើជាគ្រីស្តបរិស័ទដែលមានសេចក្តីក្លាហាន ដើម្បីរស់នៅក្នុងសង្គមបច្ចុប្បន្ននេះដែលណែនាំឲ្យយើងវង្វេង។ តាំងពីដើមរៀងមក ធម្មទេសនារបស់ព្រះយេស៊ូផ្ទុយពីសង្គម ផ្ទុយពីធម្មជាតិរបស់មនុស្ស ព្រះយេស៊ូ

បានណែនាំឲ្យមនុស្សយើងពោរពេញដោយរបៀបថ្មី ដែលខុសពីអ្វីដែលយើងស្គាល់នៅក្នុងពិភពបច្ចុប្បន្ននេះ។ ទោះបីយើងមានសញ្ញាបត្រ យើងមានចំណេះដឹង ជីវិតរបស់យើងមិនអាចសម្រាកបានទេ គ្រីស្តបរិស័ទគ្មានសិទ្ធិចូលនិវត្តន៍ ដោយសារយើងបានទទួលអគ្គសញ្ញាជាបុត្រធីតារបស់ព្រះជាម្ចាស់ នៅក្នុងពិធីជ្រមុជទឹកហើយ។

និស្សិតសាលាអប់រំជំនឿសន្តយ៉ូស្វីន ជំនាន់ទីបីនេះ យើងមានគ្រប់វ័យ គ្រប់ប្រភេទ តែយើងបានខិតខំរៀន ដែលជាគំរូពិសេសសម្រាប់ក្មេងៗ។ ជីវិតជាគ្រីស្តបរិស័ទ ជាការប្រយុទ្ធជានិច្ច រវាងខ្ញុំនឹងខ្ញុំ រវាងខ្ញុំនឹងព្រះជាម្ចាស់ ពេលព្រះជាម្ចាស់ឲ្យខ្ញុំទៅខាងលិចខ្ញុំទៅខាងកើត រវាងខ្ញុំនឹងលោកីយ៍ លោកកីយ៍ណែនាំឲ្យយើងស្រួលប៉ុន្តែធម្មទេសនារបស់ព្រះយេស៊ូឲ្យខ្ញុំស្រឡាញ់សត្រូវ ធ្វើជាអំបិល ធ្វើជាពន្លឺ។ តែជាធម្មទេសនាដែលណែនាំឲ្យយើងភ្ញាក់ស្មារតីពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីចូលនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ គឺ"**ព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ កែប្រែចិត្តគំនិតនិងជឿលើដំណឹងល្អចុះ**" ។ ពេលព្រះយេស៊ូទេសនាហើយ ព្រះអង្គចាប់ផ្តើមស្វាគមន៍គេ មាននាយទាហានម្នាក់ដែលកូនចៅគាត់ឈឺ ព្រះយេស៊ូមានព្រះបន្ទូលភ្លាមថា "**ខ្ញុំនឹងទៅមើលគាត់ឲ្យគាត់ជា**" ប៉ុន្តែដោយសារនាយទាហានម្នាក់នោះបង្ហាញជំនឿធ្វើឲ្យព្រះយេស៊ូស្ងើចសរសើរណាស់ ណែនាំឲ្យកូនទាហានរបស់គាត់ជាសះស្បើយពីជំងឺ។ ព្រះយេស៊ូចាំឲ្យអ្នកជំងឺមកជួប អ្នកដែលខ្មោចចូល ដែលវង្វេង អ្នកដែលអស់សង្ឃឹម អ្វីដែលព្រះអង្គបានប្រកាសក្នុងធម្មទេសនា ព្រះយេស៊ូចាប់ផ្តើមអនុវត្តភ្លាម។ ដោយសារដំណឹងល្អ ជាដំណឹងសម្រាប់អ្នកក្រីក្រ មិនមែនសម្រាប់តែអ្នកដែលមានចំណេះដឹងខ្ពស់ ជាអ្នកក្រីក្រដែលគ្មានទីពឹង ដែលគ្មានអ្វីៗទាំងអស់ ដើម្បីទទួលស្គាល់តម្លៃជីវិតរបស់គេ ឲ្យគេរកឃើញទីពឹងថ្មីគឺ ព្រះសហគមន៍ ព្រះបន្ទូល និងព្រះយេស៊ូគ្រីស្តផ្ទាល់។

ឲ្យយើងរស់តាមរបៀបព្រះយេស៊ូ ដើរតាមរបៀបព្រះអង្គ ពេលខ្លះណែនាំឲ្យយើងឈឺចិត្ត ប៉ុន្តែយើងដឹងថាចុងក្រោយបំផុតយើងទទួលរង្វាន់យ៉ាងធំ គឺជីវិតយ៉ាងពិតប្រាកដ។ អាម៉ែន៕